ក្រសួងអប់រំរដ្ឋ NSW

# សៀវភៅមគ្គុទ្ទេសក៍អំពីវិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ និងថ្នាក់សិស្សមានទេពកោសល្យ

វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ និងថ្នាក់សិស្សមានទេពកោសល្យ គឺជា**ទីតាំងសាលាឯកទេសនានាដែលប្រមូលផ្តុំសិស្សមានសក្តានុពលខ្ពស់ និងមានទេពកោសល្យ។**

ការរៀនជាមួយមិត្តរួមថ្នាក់ដែលមានសមត្ថភាពស្រដៀងគ្នាជួយដល់ការអភិវឌ្ឍន៍ការសិក្សា និងសុខុមាលភាពរបស់សិស្ស។

សិស្សនៅតែធ្វើតាមកម្មវិធីសិក្សារបស់ NSW ប៉ុន្តែគ្រូបង្រៀនអាចប្រើយុទ្ធសាស្ត្របង្រៀនពិសេសសម្រាប់អ្នកសិក្សាដែលមានសក្តានុពលខ្ពស់ និងមានទេពកោសល្យ។

នៅក្នុងថ្នាក់សិស្សមានទេពកោសល្យអប់រំសិស្សប្រុសស្រីរួមគ្នានីមួយៗ និងវិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យនឹងមានកន្លែងស្មើគ្នាសម្រាប់សិស្សស្រី និងសិស្សប្រុស។

## វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ

វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ មាន4ប្រភេទ៖

- **វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យពេញលេញ** - ទាំងនេះគឺជាសាលារៀនដែលសិស្សទាំងអស់ត្រូវបានជ្រើសរើសដោយផ្អែកលើការធ្វើតេស្តផ្តល់កន្លែងរៀន
- **វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យដោយផ្នែក** - ទាំងនេះគឺជាសាលារៀនដែលមានចម្រុះទៅដោយសិស្សដែលបានជ្រើសរើស និងសិស្សក្នុងតំបន់មូលដ្ឋាន
- **វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យផ្នែកកសិកម្ម** - ទាំងនេះគឺជាសាលារៀនដែលសង្កត់ធ្ងន់លើការសិក្សាផ្នែកកសិកម្ម ហើយសិស្សទាំងអស់ត្រូវបានជ្រើសរើសទៅតាមសមត្ថភាពសិក្សារបស់ពួកគេ។ សាលារៀនទាំងនេះមួយចំនួនក៏ផ្តល់កន្លែងស្នាក់នៅ និងអាហារផងដែរជាកន្លែងដែលសិស្សរស់នៅក្នុងបរិវេណសាលា។
- **វិទ្យាល័យ Aurora College** - ទាំងនេះគឺជាថ្នាក់ជ្រើសរើសសិស្សមានទេពកោសល្យរៀនតាមអនឡាញ។ ថ្នាក់រៀនទាំងនេះត្រូវបានផ្តល់នៅតាមវិទ្យាល័យសាធារណៈក្នុងមូលដ្ឋាននៅតាមទីជនបទ និងតំបន់ដាច់ស្រយាល។

## ថ្នាក់សិស្សមានទេពកោសល្យ

ថ្នាក់សិស្សមានទេពកោសល្យគឺសម្រាប់សិស្សមានសក្តានុពលខ្ពស់ និងមានទេពកោសល្យថ្នាក់ទី5 និងទី6។ ថ្នាក់រៀនទាំងនេះត្រូវបានផ្តល់នៅតាមសាលាបឋមសិក្សាសាធារណៈមួយចំនួននៅទូទាំងរដ្ឋ NSW។

វិទ្យាល័យ Aurora College ផ្តល់ជូនថ្នាក់រៀនតាមអនឡាញសម្រាប់សិស្សមានទេពកោសល្យ នៅទីជនបទ និងតំបន់ដាច់ស្រយាលក្នុងសាលាបឋមសិក្សាក្នុងមូលដ្ឋានរបស់ពួកគេ។

## តើសាលារៀន និងថ្នាក់រៀនទាំងនេះមានទីតាំងនៅកន្លែងណា?

វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ និងថ្នាក់សិស្សមានទេពកោសល្យមាននៅទូទាំងតំបន់ជុំវិញទីក្រុង ភូមិភាគ និងទីជនបទរដ្ឋ NSW។ សូមពិនិត្យមើលផែនទីខាងក្រោមសម្រាប់សាលារៀនមួយនៅជិតអ្នក។

- ស្វែងរកថ្នាក់សិស្សមានទេពកោសល្យ
- ស្វែងរកវិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ


CC BY

## តើខ្ញុំដឹងដោយរបៀបណាថាវាជាកន្លែងត្រឹមត្រូវសម្រាប់កូនរបស់ខ្ញុំ?

តើកូនរបស់អ្នក៖

- រីករាយក្នុងការរៀនសូត្រ
- មានការចង់ដឹងចង់ឃើញខ្លាំង
- បង្ហាញការចងចាំល្អ
- សួរសំណួរស្មុគស្មាញនានា
- ទាមទារការធ្វើដដែលៗតិចជាង នៅពេលរៀនអ្វីថ្មីៗ
- បង្ហាញវិធីច្នៃប្រឌិតនៃការគិត
- ផ្តោតខ្លាំងលើផ្នែកដែលពួកគេចាប់អារម្មណ៍ ឬចំណង់ចំណូលចិត្ត?

ប្រសិនបើចំណុចទាំងនេះស្តាប់ទៅត្រូវសមនឹងកូនរបស់អ្នក ថ្នាក់សិស្សមានទេពកោសល្យ ឬវិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យអាចជាកន្លែងត្រឹមត្រូវ។

## តើខ្ញុំដាក់ពាក្យសុំដោយរបៀបណា?

ឪពុកម្តាយដាក់ពាក្យសុំក្នុងអំឡុងពេលដាក់ពាក្យតាមអនឡាញនៅតាមគេហទំព័រ៖ shsoc.education.nsw.gov.au

## ការចូលរៀនឆ្នាំ 2027 ក្នុងថ្នាក់សិស្សមានទេពកោសល្យ ឬវិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ

អំឡុងពេលដាក់ពាក្យសុំចូលរៀនឆ្នាំ 2027 គឺចាប់ពី**ថ្ងៃទី6 ខែវិច្ឆិកា ឆ្នាំ2025** ដល់**ថ្ងៃទី20 ខែកុម្ភៈ ឆ្នាំ2026**។

### តើកូនរបស់ខ្ញុំនឹងចូលរៀននៅថ្នាក់ទីប៉ុន្មាននៅពេលខ្ញុំដាក់ពាក្យសុំ?

**ថ្នាក់សិស្សមានទេពកោសល្យ**

ឪពុកម្តាយដាក់ពាក្យសុំនៅពេលកូនរបស់ពួកគេរៀនជិតចប់ថ្នាក់ទី3 ក្នុងឆ្នាំ2025 ឬនៅដើមថ្នាក់ទី4 ក្នុងឆ្នាំ2026។

**វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ**

ឪពុកម្តាយដាក់ពាក្យសុំនៅពេលកូនរបស់ពួកគេរៀនជិតចប់ថ្នាក់ទី5 ក្នុងឆ្នាំ2025 ឬនៅដើមថ្នាក់ទី6 ក្នុងឆ្នាំ2026។

ស្វែងយល់បន្ថែមនៅលើគេហទំព័ររបស់យើងអំពីដំណើរការដាក់ពាក្យសុំ និងតម្រូវការស្នាក់នៅថាតើអ្នកណាអាចដាក់ពាក្យសុំសម្រាប់ថ្នាក់សិស្សមានទេពកោសល្យ និង អ្នកណាអាចដាក់ពាក្យសុំសម្រាប់វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ។

## ការធ្វើតេស្តផ្តល់កន្លែងរៀន

បន្ទាប់ពីអ្នកដាក់ពាក្យសុំរួចហើយ កូនរបស់អ្នកត្រូវតែអង្គុយធ្វើតេស្ត។ បន្ទាប់មក សិស្សត្រូវបានជ្រើសរើសសម្រាប់ការផ្តល់កន្លែងរៀនដោយផ្អែកលើការធ្វើតេស្តរបស់ពួកគេ។

### តើការធ្វើតេស្តត្រូវធ្វើនៅពេលណា?

ការធ្វើតេស្តនឹងមានរយៈពេល2 ថ្ងៃ៖

**ការធ្វើតេស្តវិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ៖ ថ្ងៃសុក្រ ទី1 ខែឧសភា និងថ្ងៃសៅរ៍ ទី2 ខែឧសភា ឆ្នាំ 2026**

**ការធ្វើតេស្តថ្នាក់សិស្សមានទេពកោសល្យ៖ ថ្ងៃសុក្រ ទី8 ខែឧសភា និងថ្ងៃសៅរ៍ ទី9 ខែឧសភា 2026**

សិស្សមកចូលរួមថ្ងៃធ្វើតេស្តមួយ ហើយ**មិន**ចាំបាច់យកកុំព្យូទ័ររបស់ពួកគេ មកអង្គុយធ្វើតេស្តផ្តល់កន្លែងរៀនតាមកុំព្យូទ័រទេ។

## តើការធ្វើតេស្តនឹងត្រូវធ្វើឡើងនៅឯណា?

ការធ្វើតេស្តភាគច្រើននឹងធ្វើឡើងនៅក្នុងវិទ្យាល័យរដ្ឋក្នុងរដ្ឋ NSW តាមតំបន់។ សិស្សនឹងត្រូវបានបែងចែកទីតាំងមណ្ឌលធ្វើតេស្តដោយផ្អែកលើកន្លែងដែលពួកគេចូលរៀន។ ឪពុកម្តាយត្រូវនាំកូនរបស់ពួកគេទៅមណ្ឌលធ្វើតេស្តនោះនៅថ្ងៃធ្វើតេស្ត។

## តើមានអ្វីខ្លះនៅក្នុងការធ្វើតេស្ត?

ការធ្វើតេស្តវាយតម្លៃថាតើសិស្សយល់ច្បាស់ពីអ្វីដែលពួកគេអានឬអត់ ហេតុផលដោយប្រើគណិតវិទ្យា និងជំនាញគិតរបស់ពួកគេ។ បេក្ខជនសម្រាប់វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ ក៏ត្រូវបានធ្វើតេស្តលើជំនាញសរសេររបស់ពួកគេផងដែរ។

ស្វែងយល់បន្ថែមនៅ៖ ការធ្វើតេស្តផ្តល់កន្លែងរៀន។

# តើខ្ញុំនឹងដឹងអំពីលទ្ធផលរបស់កូនខ្ញុំនៅពេលណា?

បន្ទាប់ពីកូនរបស់អ្នកអង្គុយធ្វើតេស្ត អ្នកនឹងទទួលបានអ៊ីមែលមួយនៅក្នុងត្រីមាសទី3 ជាមួយនឹងលទ្ធផលតេស្តរបស់ពួកគេ និងជំហានបន្ទាប់នានា។ ប្រសិនបើកូនរបស់អ្នកត្រូវបានផ្តល់កន្លែងរៀន អ្នកនឹងទទួលបានព័ត៌មានអំពីរបៀបចុះឈ្មោះ។

# គំរូការផ្តល់កន្លែងរៀនដែលមានសមធម៌

គំរូការផ្តល់កន្លែងរៀនដែលមានសមធម៌ ជួយសិស្សទាំងអស់ឱ្យមានលទ្ធភាពទទួលបានកន្លែងរៀនដោយយុត្តិធម៌នៅវិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ និងថ្នាក់សិស្សមានទេពកោសល្យ។

នៅក្រោមគំរូនេះ កន្លែងសិស្សរៀនរហូតដល់ទៅ20% នៅវិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ និងថ្នាក់សិស្សមានទេពកោសល្យនីមួយៗ ត្រូវបានធ្វើរក្សាទុកសម្រាប់សិស្សមានសក្តានុពលខ្ពស់ និងមានទេពកោសល្យ៖

- មកពីតំបន់ឧត្តមភាពអប់រំសង្គមទាប
- មកពីប្រវត្តិជនជាតិដើម Aboriginal និង/ឬ អ្នកកោះ Torres Strait
- មកពីទីជនបទ និងតំបន់ដាច់ស្រយាល
- មានពិការភាព។

កន្លែងដែលបានរក្សាទុក ត្រូវបានផ្តល់ជូនសិស្សដោយផ្អែកលើការបំពេញតេស្តរបស់ពួកគេនៅក្នុងការធ្វើតេស្តផ្តល់កន្លែងរៀន។

ស្វែងយល់បន្ថែមនៅ លទ្ធភាពទទួលបានកន្លែងរៀនដោយយុត្តិធម៌។

**ការគាំទ្រសិស្សមានទេពកោសល្យនៅសាលារដ្ឋក្នុងរដ្ឋ NSW ទាំងអស់។**

វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ និងថ្នាក់សិស្សមានទេពកោសល្យ គឺជាវិធីមួយក្នុងចំណោមវិធីនានាដែលក្រសួងអប់រំ NSW គាំទ្រសិស្សមានសក្តានុពលខ្ពស់ និងមានទេពកោសល្យប៉ុណ្ណោះ។

សិស្សមានសក្តានុពលខ្ពស់ និងមានទេពកោសល្យត្រូវបានគាំទ្រនៅក្នុងសាលារៀនរដ្ឋក្នុងរដ្ឋ NSW ទាំងអស់ដើម្បីឈានដល់សក្តានុពលពេញលេញរបស់ពួកគេ។ ស្វែងយល់បន្ថែមអំពីគោលនយោបាយអប់រំសិស្សមានសក្តានុពលខ្ពស់ និងមានទេពកោសល្យរបស់ក្រសួង។

## ត្រូវការព័ត៌មានបន្ថែម?

សូមពិនិត្យមើលគេហទំព័រខាងក្រោម សម្រាប់ព័ត៌មានបន្ថែម។

## គេហទំព័រសម្រាប់ឪពុកម្ដាយ និងអ្នកថែទាំ

- **វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ និងថ្នាក់សិស្សមានទេពកោសល្យ៖** education.nsw.gov.au/shs-oc
- **វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ៖** education.nsw.gov.au/shs-yr7
- **ថ្នាក់សិស្សមានទេពកោសល្យ៖** education.nsw.gov.au/oc

## គេហទំព័រសម្រាប់សិស្ស

- **ព័ត៌មានសម្រាប់សិស្សអំពីវិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ និងថ្នាក់សិស្សមានទេពកោសល្យ៖** edu.nsw.link/shs-oc-students
- **ការដាក់ពាក្យសុំសម្រាប់ថ្នាក់សិស្សមានទេពកោសល្យ៖** មជ្ឈមណ្ឌលធនធានសិស្ស៖ edu.nsw.link/OChub
- **ការដាក់ពាក្យសុំសម្រាប់វិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ៖** មជ្ឈមណ្ឌលធនធានសិស្ស៖ edu.nsw.link/SHShub

## ប្រព័ន្ធផ្សព្វផ្សាយសង្គម

ចូលរួមជាមួយក្រុមហ្វេសប៊ុកផ្លូវការរបស់ក្រសួងរបស់យើង៖

- **ការផ្ដល់កន្លែងរៀននៅវិទ្យាល័យជ្រើសរើសសិស្សមានទេពកោសល្យ៖** edu.nsw.link/shs-fb
- **ថ្នាក់សិស្សមានទេពកោសល្យ៖** edu.nsw.link/oc-fb

## ទាក់ទងមកពួកយើង

ទាក់ទងក្រុមការងារអប់រំជ្រើសរើសសិស្សមានទេពកោសល្យ (Selective Education Team) តាមរយៈ៖

**អ៊ីមែល៖** set@det.nsw.edu.au

**ទូរសព្ទ៖** 1300 880 367

**សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ៖ 131 450**

ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ដើម្បីជួយក្នុងការសាកសួររបស់អ្នក សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ សូមប្រាប់ការីទូរសព្ទ៖

- ភាសាដែលអ្នកត្រូវការ
- លេខទូរសព្ទដែលអ្នកចង់ហៅ។

ការីទូរសព្ទនឹងហៅលេខទូរសព្ទ ក្រុមការងារអប់រំជ្រើសរើសសិស្សមានទេពកោសល្យ (1300 880 367) ហើយរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់  ដើម្បីជួយអ្នកក្នុងការសន្ទនារបស់អ្នក។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។